00367373

E159

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 08 / 2009
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 27 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និង ការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រ៊ីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN
Fabienne TRUSSES-NAPROUS

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX
Marie-Paule CANIZARÈS

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

E159

០០១/១៨ កក្កដា ២០០៧/អវតក/អជសង

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)

**បានឃើញ** វិធាន២៣ នៃវិធានផ្ទៃក្នុង អ.វ.ត.ក

**រំលឹក** ដល់ដើមបណ្តឹងរដ្ឋប្បវេណីថា ដើមបណ្តឹងរដ្ឋប្បវេណីមានបន្ទុកក្នុងការបង្ហាញភស្តុតាងទាក់ទិននឹងភាពអាចទទួលយកបាននៃពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងខ្លឹមសារនៃពាក្យបណ្តឹងរបស់ពួកគាត់។

អង្គជំនុំជម្រះសាលាដំបូង យោងលើវិធាន ២៣(១១) និង(១២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលវិធានបានចែងថា៖

> ១១. យោងទៅលើមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះអាចសម្រេចផ្តល់ឲ្យតែសំណងផ្លូវចិត្ត និងជាសមូហភាពទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ការផ្តល់សំណងនេះត្រូវធ្វើឡើងប្រឆាំងទៅនឹងទណ្ឌិត និងជាបន្ទុករបស់ទណ្ឌិត។
>
> ១២. ការផ្តល់សំណងអាចធ្វើឡើងក្រោមរូបភាពដូចខាងក្រោម៖
> ក- ការបង្គាប់ឲ្យបោះពុម្ពផ្សាយសាលក្រម ឬសាលដីកា នៅក្នុងសារព័ត៌មានសមស្របណាមួយដែលការចំណាយជាបន្ទុករបស់ទណ្ឌិត។
> ខ- ការបង្គាប់ឲ្យផ្តល់មូលនិធិដល់សកម្មភាព ឬ សេវាកម្មមិនរកប្រាក់ចំណេញណាមួយ ដែលមានគោលបំណងផ្តល់ប្រយោជន៍ដល់ជនរងគ្រោះ។ ឬ



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C • C E T C

00367375

E1/59



គ- ទម្រង់ផ្សេងទៀតនៃសំណងដែលមានលក្ខណៈសមរម្យ និងប្រហាក់ប្រហែល។

អនុលោមតាមវិធានផ្ទៃក្នុង និងកាតព្វកិច្ចបំពេញការជំនុំជម្រះឲ្យបានឆាប់រហ័ស ដូចមានចែងនៅក្នុងមាត្រា៣៣ នៃច្បាប់អ.វ.ត.ក ព្រមទាំងដើម្បីផ្តល់ដល់នីតិវិធីនៃការទាមទារសំណង និងអនុលោមតាមវិធាន៩២ និងវិធាន៩៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចំពោះមុខ អ.វ.ត.ក (អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៤)។

**សូមណែនាំដូចខាងក្រោមនេះ÷**

១. ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ត្រូវដាក់សារណាជាលាយលក្ខណ៍អក្សរ មិនឲ្យលើសពី ១០ទំព័រជាភាសាអង់គ្លេស ឬភាសាបារាំង ឬ២០ទំព័រជាភាសាខ្មែរ ត្រឹមថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០០៩ ដែលបញ្ជាក់ពីទម្រង់នៃការទាមទារសំណងផ្លូវចិត្ត និងសមូហភាព ប្រឆាំងនឹងជនជាប់ចោទ ប្រសិនបើត្រូវបានផ្តន្ទាទោស។ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីនៃក្រុមនីមួយៗ អាចសម្រេចដាក់សារណាជាលាយលក្ខណ៍អក្សររួមគ្នា ដោយមិនឲ្យលើសពី៣០ទំព័រជាភាសាអង់គ្លេសឬភាសាបារាំង ឬ៦០ទំព័រជាភាសាខ្មែរ។ មេធាវីការពារក្តីអាចដាក់សារណាតបចុងក្រោយបង្អស់ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ជាលាយលក្ខណ៍របស់ខ្លួន។

២. សូមស្នើភាគីទាំងអស់ ដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរជូនដល់អង្គជំនុំជម្រះសាលាដំបូងស្របតាមវិធាន ៩៤ នៃវិធានផ្ទៃក្នុង។ សេចក្តីសន្និដ្ឋានត្រូវដាក់ជូនដល់អង្គជំនុំជម្រះយ៉ាងយូរបំផុតនៅរសៀលថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ជាបីភាសាការងាររបស់ អ.វ.ត.ក។ ការស្នើសុំបកប្រែភាសាចំពោះសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដែលបានព្រាងដោយភាគីទៅជាពីរភាសាការងារផ្សេងទៀតរបស់




ECCC TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

អ.វ.ត.ក ត្រូវដាក់ទៅអង្គភាពបកប្រែភាសាយ៉ាងយូរបំផុតនៅថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៨។

៣. សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ របស់ការិយាល័យសហព្រះរាជអាជ្ញា និងរបស់ការិយាល័យមេធាវីការពារក្តី មិនត្រូវឲ្យលើសពីចំនួន ១៦០ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ដោយរាប់បញ្ចូលទាំងកំណត់សម្គាល់ជើងទំព័រផងដែរ ឬមិនត្រូវឲ្យលើសពីចំនួន ៣២០ ទំព័រ ជាភាសាខ្មែរ ដោយរាប់បញ្ចូលទាំងកំណត់សម្គាល់ជើងទំព័រផង។

៤. សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់ មិនត្រូវឲ្យលើសចំនួន ១៦០ ទំព័រ ជាភាសាអង់គ្លេស ឬ ភាសាបារាំង ដោយរាប់បញ្ចូលទាំងកំណត់សម្គាល់ជើងទំព័រផង ឬមិនត្រូវឲ្យលើសពីចំនួន ៣២០ ទំព័រ ជាភាសាខ្មែរដោយរាប់បញ្ចូលទាំងកំណត់សម្គាល់ជើងទំព័រ ព្រមទាំងត្រូវរួមបញ្ចូលនូវការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។ ប្រសិនបើក្រុមដើមបណ្តឹងរដ្ឋប្បវេណីមានបំណងចង់ដាក់សេចក្តីសន្និដ្ឋានជាឯកសារដាច់ដោយឡែកពីគ្នានោះ សូមអនុវត្តតាមការកំណត់ចំនួនទំព័រដូចតទៅនេះ៖

- ក. ៥២ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ឬ១០៤ទំព័រ ជាភាសាខ្មែរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១។
- ខ. ៤៤ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ឬ៨៨ទំព័រ ជាភាសាខ្មែរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២។
- គ. ៣៥ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ឬ៧០ទំព័រ ជាភាសាខ្មែរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣។



E C C C • E T C
TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE

E159

០០១/១៨ កក្កដា ២០០៧/អវតក/អជសង

ឃ. ២៩ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ឬ៥៨ទំព័រ ជាភាសាខ្មែរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤។

៥. សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបញ្ជាក់នូវអំណះអំណាងផ្លូវច្បាប់ និងអង្គហេតុដែលគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីខ្លួនបានក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី និងបញ្ជាក់ពីការទាមទារសំណងរបស់ពួកគេ។ សេចក្តីសន្និដ្ឋាននឹងជំនួសនូវការទាមទារទាំងអស់ដែលបានធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗនៅដំណាក់កាលមុន។

៦. សវនាការសម្រាប់ស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដោយផ្ទាល់មាត់របស់ភាគីនឹងចាប់ផ្តើមធ្វើនៅ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩។

ភ្នំពេញ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C B T C

និល - ណុន